ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងព័ត៌មាន
លេខ ៧៩៤ ប្រក.ពម

# ប្រកាស
# ស្តីពី
# លក្ខខណ្ឌគុណវុឌ្ឍិ និងវិជ្ជាជីវៈសារព័ត៌មាន សម្រាប់អ្នកអនុវត្តសកម្មភាពក្នុងវិស័យព័ត៌មាននិងសោតទស្សន៍

## រដ្ឋមន្ត្រីក្រសួងព័ត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៧ ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសារព័ត៌មាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ២១៧ អនក្រ.បក ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន
- បានឃើញប្រកាសលេខ២០៨៥ ប្រក.ពម ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០២៤ ស្តីពីការដាក់ឱ្យអនុវត្តធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន
- យោងតាមតម្រូវការចាំបាច់នៃការងារ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ


អគារលេខ ៦២ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
Building 62, Monivong BLVD, Sangkat Srah Chork, Khan Daun Penh, Phnom Penh E-mail:information@info.gov.kh

**ប្រការ១ .-**

ប្រកាសនេះកំណត់អំពីលក្ខខណ្ឌគុណវុឌ្ឍិ និងវិជ្ជាជីវៈសារព័ត៌មានសម្រាប់អ្នកអនុវត្តសកម្មភាពក្នុងវិស័យព័ត៌មាននិងសោតទស្សន៍ ដើម្បីពង្រឹងសណ្តាប់ធ្នាប់សារព័ត៌មាន លើកកម្ពស់វិជ្ជាជីវៈសារព័ត៌មាន និងពង្រឹងគុណភាពព័ត៌មាន សុវត្ថិភាពព័ត៌មានសម្រាប់សាធារណជន។

**ប្រការ២ .-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះអ្នកអនុវត្តសកម្មភាពក្នុងវិស័យព័ត៌មាននិងសោតទស្សន៍ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣ .-**

អ្នកអនុវត្តសកម្មភាពក្នុងវិស័យព័ត៌មាននិងសោតទស្សន៍ សំដៅលើ៖

- អង្គភាពផ្សព្វផ្សាយឯកជន ដូចជា អង្គភាពប្រកបអាជីពសារព័ត៌មានគ្រប់ជំនាញ គ្រឹះស្ថានបោះពុម្ពផ្សាយ សមាគមអ្នកសារព័ត៌មាន ក្រុមហ៊ុន/ភ្នាក់ងារផ្សាយពាណិជ្ជកម្ម និង
- អ្នកសារព័ត៌មានគ្មានអង្គភាព អ្នកផលិតមាតិកា អ្នកមានប្រជាប្រិយភាព និងអ្នកសារព័ត៌មានដែលមានលក្ខណៈប្រហាក់ប្រហែល។

## ជំពូកទី២
## ការបង្កើតអង្គភាពនិងលក្ខខណ្ឌ

**ប្រការ៤ .-**

រាល់ការស្នើសុំបង្កើតអង្គភាពផ្សព្វផ្សាយឯកជន ត្រូវអនុវត្តលក្ខខណ្ឌដូចខាងក្រោម៖

១. **ការស្នើសុំអាជ្ញាបណ្ណឬលិខិតអនុញ្ញាតពីក្រសួងព័ត៌មាន**

១.១. ការបង្កើតអង្គភាពកាសែត ទស្សនាវដ្តី ព្រឹត្តិបត្រ បោះពុម្ពផ្សាយ និងគេហទំព័រត្រូវមានការកំណត់រចនាសម្ព័ន្ធ ដូចខាងក្រោម៖

- ចាងហ្វាងការផ្សាយ ឬបណ្ណាធិការ ឬម្ចាស់អង្គភាព
- និពន្ធនាយក
- ផ្នែករដ្ឋបាល
- ផ្នែកហិរញ្ញវត្ថុ
- ផ្នែកទីផ្សារ
- ផ្នែកសារព័ត៌មាន។

១.២. ការបង្កើតស្ថានីយវិទ្យុអេហ្វអ៊ឹម ទូរទស្សន៍ និងគេហទំព័រ ត្រូវមានការកំណត់រចនាសម្ព័ន្ធ ដូចខាងក្រោម៖

- នាយកស្ថានីយ ឬម្ចាស់អង្គភាព
- នាយកការផ្សាយ
- ផ្នែកផលិតកម្មវិធី

- ផ្នែកព័ត៌មាន
- ផ្នែកពិធីករ
- ផ្នែកបច្ចេកទេស
- ផ្នែករដ្ឋបាល
- ផ្នែកហិរញ្ញវត្ថុ
- ផ្នែកទីផ្សារ។

១.៣. ការបង្កើតប្រព័ន្ធផ្សព្វផ្សាយបែបថ្មី ត្រូវមានរចនាសម្ព័ន្ធ និងការទទួលខុសត្រូវដូចមានចែងក្នុងចំណុច១.១ និងចំណុច១.២ នៃប្រការ៤ ខាងលើ។

២. **អំពីគុណវុឌ្ឍិនៃមុខតំណែង**

២.១. ចាងហ្វាងការផ្សាយ/នាយកការផ្សាយ និងនិពន្ធនាយក ត្រូវមានលក្ខខណ្ឌដូចខាងក្រោម៖

- ត្រូវមានអាយុចាប់ពី២៥ឆ្នាំឡើង
- ត្រូវមានសញ្ញាបត្របរិញ្ញាបត្រ ឬសញ្ញាបត្រសមមូលឡើងទៅ
- ត្រូវមានវិញ្ញាបនបត្របញ្ជាក់ការសិក្សាវិជ្ជាជីវៈសារព័ត៌មាន និងសោតទស្សន៍ពីក្រសួងព័ត៌មានឬស្ថាប័ន ដែលមានការទទួលស្គាល់ពីក្រសួងព័ត៌មាន និង/ឬត្រូវឆ្លងកាត់ការវាយតម្លៃកម្រិតចំណេះដឹងពីក្រសួងព័ត៌មាន។ ករណី និពន្ធនាយក ត្រូវមានត្រូវមានបរិញ្ញាបត្រសារព័ត៌មាន
- មានបទពិសោធបំរើការងារខាងនិពន្ធ និងយកព័ត៌មានយ៉ាងតិច ៣ឆ្នាំ (ត្រូវមានលិខិតបញ្ជាក់ទទួលស្គាល់ពីសាមីអង្គភាព)
- លិខិតថ្កោលទោស
- ត្រូវមានលិខិតបញ្ជាក់ទីកន្លែងរស់នៅ និងកិរិយាមារយាទពីឃុំ-សង្កាត់
- ត្រូវមានលិខិតបញ្ជាក់សុខភាពផ្លូវការ
- មិនធ្លាប់មានការតវ៉ាជាអាទិ៍លើអត្ថបទ ឬវីដេអូ ឬរូបភាព ឬវប្បធម៌ ឬក្បួនខ្នាតអក្សរសាស្ត្រនិងភាសាជាតិខ្មែរ ដែលរំលោភទៅលើក្រមសីលធម៌វិជ្ជាជីវៈ។

២.២. អ្នកយកព័ត៌មាន

- ត្រូវមានអាយុចាប់ពី២០ឆ្នាំឡើងទៅ
- ត្រូវមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រដែលមានតម្លៃសមមូលឡើងទៅ
- ត្រូវមានវិញ្ញាបនបត្របញ្ជាក់ការសិក្សាវិជ្ជាជីវៈសារព័ត៌មាន និងសោតទស្សន៍ពីក្រសួងព័ត៌មាន ឬស្ថាប័នដែលមានការទទួលស្គាល់ដោយក្រសួងព័ត៌មាន និង/ឬត្រូវឆ្លងកាត់ការវាយតម្លៃកម្រិតចំណេះដឹងពីក្រសួងព័ត៌មាន
- ធ្លាប់បម្រើការងារជាអ្នកយកព័ត៌មានយ៉ាងតិច១ឆ្នាំ ដោយត្រូវមានលិខិតបញ្ជាក់ទទួលស្គាល់ពីសាមីអង្គភាព

- ត្រូវមានលិខិតបញ្ជាក់ទីកន្លែងរស់នៅ និងកិរិយាមារយាទពីឃុំ-សង្កាត់
- ត្រូវមានលិខិតបញ្ជាក់សុខភាពផ្លូវការ
- មិនធ្លាប់មានការតវ៉ាជាអាទិ៍លើអត្ថបទ ឬវីដេអូ ឬរូបភាព ឬវប្បធម៌ ឬក្បួនខ្នាតអក្សរសាស្ត្រនិងភាសាជាតិខ្មែរ ដែលរំលោភទៅលើក្រមសីលធម៌វិជ្ជាជីវៈ។

២.៣. ពិធីករ

- ត្រូវមានអាយុចាប់ពី២០ឆ្នាំឡើងទៅ
- ត្រូវមានការសិក្សាចាប់ពីថ្នាក់ទី១២ ឡើងទៅ ឬការសិក្សាដែលមានតម្លៃសមមូល
- ត្រូវមានវិញ្ញាបនបត្របញ្ជាក់ការសិក្សាវិជ្ជាជីវៈសារព័ត៌មាន និងសោតទស្សន៍ពីក្រសួងព័ត៌មាន ឬស្ថាប័នអប់រំ ឬសមាគមសារព័ត៌មាន ដែលមានការទទួលស្គាល់ដោយក្រសួងព័ត៌មាន និង/ឬត្រូវឆ្លងកាត់ការធ្វើតេស្តពីក្រសួងព័ត៌មាន
- ធ្លាប់បម្រើការងារជាពិធីករយ៉ាងតិច ១ឆ្នាំឡើងទៅ ដែលមានលិខិតបញ្ជាក់ទទួលស្គាល់ពីសាមីអង្គភាព
- ត្រូវមានលិខិតបញ្ជាក់ទីកន្លែងរស់នៅ និងកិរិយាមារយាទពីឃុំ-សង្កាត់
- ត្រូវមានលិខិតបញ្ជាក់សុខភាពផ្លូវការ
- មិនធ្លាប់មានការតវ៉ាទៅលើការរៀបចំខ្លួនមិនបានល្អ ឬសម្លៀកបំពាក់មិនសមរម្យស្របទៅតាមកម្មវិធី ឬឫកពាឆ្គាំឆ្គង ឬនិយាយស្តីនិងប្រើប្រាស់ភាសាខ្មែរមិនបានសមរម្យ និងមិនត្រឹមត្រូវតាមអក្ខរាវិរុទ្ធ។

២.៤. អ្នកសារព័ត៌មានគ្មានអង្គភាព អ្នកផលិតមាតិកា អ្នកមានប្រជាប្រិយភាព

- ត្រូវមានអាយុចាប់ពី២០ឆ្នាំឡើងទៅ
- ត្រូវមានសញ្ញាបត្របរិញ្ញាបត្រ និងសញ្ញាបត្រដែលមានតម្លៃសមមូលឡើងទៅ
- ត្រូវមានវិញ្ញាបនបត្របញ្ជាក់ការសិក្សាវិជ្ជាជីវៈសារព័ត៌មាន និងសោតទស្សន៍ពីក្រសួងព័ត៌មាន ឬស្ថាប័ន ដែលមានការទទួលស្គាល់ដោយក្រសួងព័ត៌មាន
- ធ្លាប់បម្រើការងារជាអ្នកយកព័ត៌មានយ៉ាងតិច១ឆ្នាំ ដែលមានលិខិតបញ្ជាក់ទទួលស្គាល់ពីសាមីអង្គភាព ដែលខ្លួនសរសេរអត្ថបទផ្សាយ ឬកិច្ចសន្យាការងារចុងក្រោយ
- ធ្លាប់បានសរសេរអត្ថបទព័ត៌មានឱ្យអង្គភាពសារព័ត៌មានយ៉ាងតិចចំនួន៣(បី)
- ត្រូវមានលិខិតបញ្ជាក់ទីកន្លែងរស់នៅ និងកិរិយាមារយាទពីឃុំ-សង្កាត់
- ត្រូវមានលិខិតបញ្ជាក់សុខភាពផ្លូវការ
- មិនធ្លាប់មានការតវ៉ាជាអាទិ៍លើអត្ថបទ ឬវីដេអូ ឬរូបភាព ឬវប្បធម៌ ឬក្បួនខ្នាតអក្សរសាស្ត្រ និងភាសាជាតិខ្មែរ ដែលរំលោភទៅលើក្រមសីលធម៌វិជ្ជាជីវៈ។

២.៥. អ្នកបច្ចេកទេស

- ត្រូវមានសញ្ញាបត្របរិញ្ញាបត្របច្ចេកទេស ឬសញ្ញាបត្រសមមូលឡើងទៅ ឬ
- ធ្លាប់មានបទពិសោធបម្រើការងារផ្នែកបច្ចេកទេសយ៉ាងតិច៥ឆ្នាំ
- ត្រូវមានលិខិតបញ្ជាក់ទីកន្លែងរស់នៅ និងកិរិយាមារយាទពីឃុំ-សង្កាត់។

## ជំពូកទី៣
## ការទទួលខុសត្រូវនិងការដកហូត

**ប្រការ៥ .-**

រូបវន្តបុគ្គលនិងនីតិបុគ្គល ដូចមានចែងក្នុងប្រការ៤នៃប្រកាសនេះ ត្រូវ៖

១. គោរពតាមរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីរបបសារព័ត៌មាន ធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន ច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងកិច្ចសន្យាអាជីវកម្មដែលបានតម្កល់ទុកនៅក្រសួងព័ត៌មាន

២. ស្នើសុំការអនុញ្ញាតពីក្រសួងព័ត៌មានលើរាល់ការផ្លាស់ប្តូរព័ត៌មានរបស់អង្គភាព ការជួលម៉ោងផ្សាយ ការផ្លាស់ប្តូរមធ្យោបាយផ្សាយ និងការនាំចូល ការរៀបចំដំឡើង និងការផ្លាស់ប្តូរបរិក្ខារនិងទីតាំងស្ថានីយ

៣. គោរពម៉ឺងម៉ាត់ក្រមសីលធម៌ និងវិជ្ជាជីវៈសារព័ត៌មាន។ ករណីមានការប្រព្រឹត្តខុស នាយកការផ្សាយ និង/ឬបណ្ណាធិការ និង/ឬម្ចាស់អង្គភាព និង/ឬនាយកស្ថានីយ និង/ឬនិពន្ធនាយក និង/ឬអ្នកយកព័ត៌មាន និង/ឬពិធីករ និង/ឬអ្នកសារព័ត៌មានគ្មានអង្គភាព និង/ឬអ្នកផលិតមាតិកា និង/ឬអ្នកមានប្រជាប្រិយភាពត្រូវទទួលយកការស្តីបន្ទោស ឬការព្រមានជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់

៤. បង្ហាញអំពីអត្តសញ្ញាណរបស់អង្គភាពនិងសាមីខ្លួនឱ្យបានច្បាស់លាស់នៅពេលប្រតិបត្តិការការងារចំពោះនាយកការផ្សាយ និពន្ធនាយក អ្នកយកព័ត៌មាន ពិធីករ និងអ្នកសារព័ត៌មានគ្មានអង្គភាព អ្នកផលិតមាតិកា និងអ្នកមានប្រជាប្រិយភាព

៥. រក្សាទុកមាតិកានិងខ្លឹមសារឬអត្ថបទ ដែលផ្សព្វផ្សាយក្នុងរយៈពេល៣ខែ។

**ប្រការ៦ .-**

ក្រសួងព័ត៌មាន ដកហូតការទទួលស្គាល់គុណវុឌ្ឍិពីរូបវន្តនិងនីតិបុគ្គល ក្នុងករណីប្រព្រឹត្តផ្ទុយនឹងប្រកាសនេះ។

ក្រសួងព័ត៌មានផ្អាកជាបណ្តោះអាសន្នឬបញ្ចប់សុពលភាពអាជ្ញាបណ្ណ ចំពោះអ្នកអនុវត្តសកម្មភាពក្នុងវិស័យព័ត៌មាននិងសោតទស្សន៍ ដែលរំលោភទៅលើរដ្ឋធម្មនុញ្ញនិងច្បាប់ស្តីពីរបបសារព័ត៌មាន ត្រង់កថាខណ្ឌទី១១ នៃមាត្រា៧ និងមាត្រា១២ ចែងអំពីអាជ្ញាបណ្ណ និងកិច្ចសន្យា។

**ប្រការ៧ .-**

ក្រសួងព័ត៌មាននឹងធ្វើការតាមដាន វាយតម្លៃ និងលើកសរសើរចំពោះការអនុវត្តក្រមសីលធម៌ និងវិជ្ជាជីវៈសារព័ត៌មាន។ រូបវន្តបុគ្គល ឬនីតិបុគ្គលដូចមានចែងក្នុងប្រការ៤ ខាងលើ ដែលទទួលបានការវិនិច្ឆ័យ វាយតម្លៃ និងលើកសរសើរនឹងទទួលបាននូវការលើកទឹកចិត្តជាអាទិ៍៖

១. ទទួលបានបណ្ណសារព័ត៌មានដោយឡែក

២. ជ្រើសរើសជាបេក្ខភាពចូលរួមក្នុងព្រឹត្តិការណ៍ធំៗ របស់ជាតិនិងអន្តរជាតិ

៣. ជ្រើសរើសជាបេក្ខភាពក្នុងការធ្វើវិក្រឹត្យការ បណ្តុះបណ្តាលបន្តលើមុខជំនាញវិជ្ជាជីវៈសារព័ត៌មានទាំងក្នុងនិងក្រៅប្រទេស

៤. ជ្រើសរើសជាបេក្ខភាពដើម្បីបំពេញទស្សនកិច្ចការងារក្នុងនិងក្រៅប្រទេស

៥. ជ្រើសរើសជាបេក្ខភាពវាគ្មិនសម្រាប់ចែករំលែកបទពិសោធលើវិស័យនេះ
៦. ជ្រើសរើសជាបេក្ខភាពក្នុងការលើកសរសើរ។

## ជំពូកទី៤
## អន្តរប្បញ្ញត្តិ

**ប្រការ៨ .-**

បន្ទាប់ពីប្រកាសនេះត្រូវបានដាក់ឱ្យអនុវត្ត ចាងហ្វាងការផ្សាយ ឬនាយកការផ្សាយ ឬបណ្ណាធិការ ឬនាយកស្ថានីយ ឬម្ចាស់អង្គភាព និពន្ធនាយក អ្នកយកព័ត៌មាន ពិធីករ អ្នកសារព័ត៌មានគ្មានអង្គភាព អ្នកផលិតមាតិកា អ្នកមានប្រជាប្រិយភាពនិងអ្នកបច្ចេកទេស ដែលបានចុះបញ្ជីនៅក្រសួងព័ត៌មានរួចហើយ ដែលមានបំណងចង់បានការទទួលស្គាល់គុណវុឌ្ឍិពីក្រសួងព័ត៌មាន ត្រូវមកបំពេញលក្ខខណ្ឌតាមខ្លឹមសារនៃប្រកាសនេះ។

ចំពោះអង្គភាពផ្សព្វផ្សាយឯកជនទាំងអស់ដែលបានចុះបញ្ជីនិងកំពុងដំណើរការ ដោយមិនទាន់មានវចនាសម្ព័ន្ធសមស្របតាមប្រកាសនេះ ក្រសួងព័ត៌មានទុករយៈពេល១ឆ្នាំ ដើម្បីធ្វើការកែសម្រួលឱ្យបានស្របតាមប្រកាសនេះ។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**ប្រការ៩ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អធិការនៃអធិការដ្ឋាន ប្រធានអង្គភាពក្រោមឱវាទក្រសួងព័ត៌មាន ប្រធានមន្ទីរព័ត៌មានរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៧ កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០២៥

**រដ្ឋមន្ត្រី**

**នេត្រ ភក្ត្រា**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ